www.xtrapapers.com

M12/1/A1KHM/SP1/KHM/TZ0/XX

22120535

International Baccalaureate®
Baccalauréat International
Bachillerato Internacional

**KHMER A1 – STANDARD LEVEL – PAPER 1**
**KHMER A1 – NIVEAU MOYEN – ÉPREUVE 1**
**KHMER A1 – NIVEL MEDIO – PRUEBA 1**

Thursday 10 May 2012 (morning)
Jeudi 10 mai 2012 (matin)
Jueves 10 de mayo de 2012 (mañana)

1 hour 30 minutes / 1 heure 30 minutes / 1 hora 30 minutos

---

INSTRUCTIONS TO CANDIDATES

- Do not open this examination paper until instructed to do so.
- Write a commentary on one passage only. It is not compulsory for you to respond directly to the guiding questions provided. However, you may use them if you wish.
- The maximum mark for this examination paper is *[25 marks]*.

INSTRUCTIONS DESTINÉES AUX CANDIDATS

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez un commentaire sur un seul des passages. Le commentaire ne doit pas nécessairement répondre aux questions d'orientation fournies. Vous pouvez toutefois les utiliser si vous le désirez.
- Le nombre maximum de points pour cette épreuve d'examen est *[25 points]*.

INSTRUCCIONES PARA LOS ALUMNOS

- No abra esta prueba hasta que se lo autoricen.
- Escriba un comentario sobre un solo fragmento. No es obligatorio responder directamente a las preguntas que se ofrecen a modo de guía. Sin embargo, puede usarlas si lo desea.
- La puntuación máxima para esta prueba de examen es *[25 puntos]*.


© International Baccalaureate Organization 2012

www.xtrapapers.com



*សូមអ្នកសរសេរអត្ថាធិប្បាយទៅលើអត្ថបទតែ**មួយ** ក្នុងចំណោមអត្ថបទទាំងពីរខាងក្រោមនេះ*

**១.**

## កងកម្ម កងកែវ

នៅក្បែរជញ្ជាំង និមលបានស្តាប់ពាក្យសិទ្ធិគុណយ៉ាងយកចិត្តទុកដាក់ជាទីបំផុត ។ នាងញញឹម ... ឯសន និងផង់បានលឺសំដីចៅកម្លោះដូច្នោះ ក៏មានសេចក្តីសោមនស្សជាក្រៃលែង ។

- ក្មួយធ្វើអីចឹងដូចជាមិនសមសោះ ផង់ស្រដី ព្រោះមីងគ្មានបានផ្តល់នូវប្រយោជន៍អ្វីដល់ក្មួយឯង ។

- ខ្ញុំគ្មានចង់បានប្រយោជន៍អ្វីពីអ្នកមីងទេ មាណពឧទាន ប្រាក់នេះខ្ញុំជូនដោយចិត្តសទ្ធាជ្រះថ្លារបស់ខ្ញុំ ចំពោះអ្នករងគ្រោះ១រូប ។

- បើអីចឹង ពូត្រេកអរណាស់ ពូសននិយាយយ៉ាងរីករាយ ពូអរគុណនឹងក្មួយមិនភ្លេចទេ សូមឱ្យគុណបុណ្យព្រះរតនត្រ័យជួយចំរុងចំរើនក្មួយតរៀងទៅកុំបីឃ្លាត ។

- មីងបានលឺតែឪពុកវាសរសើរពីក្មួយឯង ផង់បន្ត សំលេងបែបនេះហើយបានជាមីងចង់ស្គាល់ក្មួយ ចុះក្មួយអញ្ជើញមកចំការដូងលោកសុផល មានការអ្វីដែរ ?

- សំនួរនេះ សិទ្ធិគុណបានប្រុងទុកមកជាស្រេច ។ បើអ្នកឆ្លើយតាមត្រង់ ថាខ្លួនជាបុត្រលោកសុផល នោះគ្រួសារពូសនមុខជាហាមឃាត់និមលមិនឱ្យទាក់ទងនឹងខ្លួនតទៅទៀតឡើយ ។

- អ្នកមីង កម្លោះតបសេចក្តី ខ្ញុំមករកទិញផ្លែត្របែកយកទៅផ្ញើម្តាយខ្ញុំឯភ្នំពេញ ម៉ាក់ខ្ញុំចូលចិត្តត្របែកក្នុងចំការនេះណាស់ ។

កសិករ និងភរិយាមានសេចក្តីពេញចិត្តលើរូបសិទ្ធិគុណខ្លាំងណាស់ ចុះទម្រាំដល់និមល តើនាងនឹងរឹតតែពេញចិត្តលើយុវជនយ៉ាងណាទៅ ? ម្ចាស់ផ្ទះបានត្អូញត្អែរថា មិនដឹងជាមានអ្វីតបស្នងសងគុណដល់ទាយកនោះទេ ។

- ណ្ហើយក្មួយ កុំប្រញាប់អី សនពោល នៅហូបបាយផ្ទះពូម្តងទៅ បំណាច់យើងរាប់អានគ្នា ។

និមលនឹកធីតពោះទុកជាមុន ព្រោះនាងគ្មានម្ហូបអ្វីជាពិសេសសំរាប់ភ្ញៀវទេ ហើយនាងកោតចិត្តឪពុកហ៊ានឃាត់គេរបៀបនេះ តែប្រសិនបើគេនៅមែន នាងត្រូវពុះពារឧសគ្គគ្រប់យ៉ាង ។

- ខ្ញុំអរគុណហើយពូ សិទ្ធិគុណឆ្លើយ ចាំថ្ងៃក្រោយចុះ ព្រោះខ្ញុំមានមិត្តម្នាក់នៅចាំក្នុងចំការ ។

និមលលឺថាមានមិត្តម្នាក់ដូច្នោះ នាងព្រួយបារម្ភក្រែងមិត្តនោះជាស្ត្រី នាងចេញពីកៀនជញ្ជាំង ។

- ប្រហែលលោកយល់ថាផ្ទះខ្ញុំចង្អៀតហើយ បានជាលោកមិនហ៊ានមកលេង ...

សំដីនាងនិមលប៉ុន្មានម៉ាត់នេះ បានប្រៀបដូចជារសជាតិនៃទឹកឃ្មុំដែលស្រក់ទៅប្រឡាក់លើផ្ទៃបេះដូងសិទ្ធិគុណតែម្តង ចំណែកពូសន និងមីងផង់ក៏នាំគ្នាសើចលាន់ឡើង ។

- អូ! មិនមែនអីចឹងទេនាង យុវជនតបភ្លាម ខ្ញុំមិនភ្លេចសុភាសិតមួយទេដែលថា ចង្អៀតចុះផ្ទះ កុំឱ្យតែចង្អៀតចិត្ត ហាៗ ហាៗ ...

ទាំងអស់គ្នាក៏សើចឡើងរឹតតែខ្លាំង តែនិមលគ្រាន់តែធ្វើញញឹមៗ ជាអាកប្បកិរិយាមួយដ៏ថ្លៃថ្នូរ អាចញ៉ាំងសោភ័ណភាពរបស់នាងឱ្យរឹតមានកំពស់ រស្មីដួងនេត្រាទាំងគូររះឡើងដូចគ្រាប់ពេជ្រ ត្របកភ្នែកងខ្ទង់ដូចចំណិតខែ បបូរមាត់ក្រហមស្រស់តាមធម្មជាតិ ថ្ពាល់ស្រីពើងស្មើតវិចិត្រដោយសុដន់ទាំងពីរដែលលាក់អាត្មាមិនដែលជួបនឹងពន្លឺព្រះអាទិត្យ ។

ប៊ីវ-ឆៃលាង, *កងកម្ម កងកែវ* (១៩៦៤)

www.xtrapapers.com



— សូមអ្នកធ្វើការអត្ថាធិប្បាយទៅលើការប្រើភាសាក្នុងរឿងខាងលើ ។

— ចូរអ្នកធ្វើការវិភាគតួអង្គ  សិទ្ធិគុណ  និងនិមលនៅក្នុងអត្ថបទ ។

— តើអ្នកនិពន្ធប្រើបច្ចេកទេសសរសេរបែបណាដើម្បីបង្ហាញគំនិតសំខាន់របស់រឿងនេះ ?

www.xtrapapers.com



២.

## គ្រឿងញៀន

គ្រឿងញៀនគឺជា    សារធាតុពាលាដែលគេ
ចម្រាញ់ពីមេ    ដំរុក្ខាវែងប្រោះ ។
ឬចម្រាញ់ពី    សារធាតុគីមីយ៉ាងស្រស់
ជាច្រវាក់ខ្មោះ    ពិសពុលដោយស្មោះគ្រោះថ្នាក់ ។
រសជាតិវាមាន    ឈ្ងុយឆ្ងាញ់ឱ្យញៀនប្រសុក្ស
បើយើងផឹកចាក់    ជក់ហឺតប្រឡាក់គ្រោះកាច ។
ថ្នាំនេះឱ្យយើង    មានចិត្តដូចភ្លើងឥតខ្លាច
ដូចព្រាយបិសាច    មហាកំណាចឫស្យា ។
ឱ្យមានកម្លាំង    ក្លាហានហើយខ្លាំដូចខ្លា
ងប់នឹងធ្វើការ    ខ្វះពិចារណាយល់ដឹង ។
ធ្វើឱ្យសម្រើប    រួមរក់ស្រួលស្រើបដល់ឆ្អឹង
ពុះតាមកំហឹង    តណ្ហាខំប្រឹងឥតឈប់ ។
ពេលសាបជាតិថ្នាំ    ឱ្យប្រកាច់ខ្លាំបាក់ស្រុប
ដូចព្រាយអាបធ្មប់    ផ្តាច់ព្រលឹងភពលោកអ្នក ។
ជនពាលប្រើប្រាស់    គ្រឿងញៀនផ្តេសផ្តាសជាផ្លាក់
ធ្វើជាអន្ទាក់    ឱ្យយើងធ្លោយធ្លាក់ចូលជ្រោះ ។
ប្រើគ្រប់វិធី    ប៉ុនប៉ងយាយីសាបព្រោះ
គ្រឿងញៀនគ្មានលស់    ឱ្យយើងរងគ្រោះដំណំ ។
លាយក្នុងភេសជ្ជៈ    ក្នុងអាហាររលាក់បន្ទំ
ឱ្យយើងសណ្តំ    អារម្មណ៍ប្រឡំខ្វាត់ខ្វែង ។
ពួកជនទុច្ចរិត    ចាប់យើងចាក់ហិតក្លិនផ្សែង
ឱ្យស្រើបឥតក្រែង    គ្មានខ្លាចរអែងនរណា ។
លុះសំរេចបាន    អំពើសាមាន្យឫស្យា
ជនពាលចាត់កាល    ញាក់តាមតណ្ហាចិត្តចង់ ។
អ្នកជុះជាតិញៀន    ធ្វើទុក្ខស្រែកឃ្លានចំណង់
មិនខ្លាចលះបង់    ក្សត់ការស្មោះត្រង់ព្រោះតែ ។
ត្រូវការជាតិថ្នាំ    រស់នៅប្រចាំថ្ងៃខែ
អ្វីក៏ធ្វើដែរ    តាមមេចៅកែប្រើប្រាស់ ។
មេធំបានដៃ    ចាត់ការកែខៃផ្តេសផ្តាស
តាមចិត្តឥតខ្មាស    លោភលន់ក្រៃក្រាស់ពាលា ។

ហនុមាន ប្ញូរិទ្ធ, *គន្លឹះអភិវឌ្ឍន៍* (២០០២)

www.xtrapapers.com



— សូមអ្នកធ្វើការអត្ថាធិប្បាយទៅលើវិធីសាស្រ្ត និង លទ្ធផលដែលអ្នកនិពន្ធប្រើ និងបង្កើតដើម្បីបង្ហាញពីផលប៉ះពាល់របស់គ្រឿងញៀន ។

— ចូរអ្នកធ្វើការពិភាក្សាទៅលើសេចក្តីសំខាន់របស់ចំណងជើងកំនាព្យនេះ ?

— សូមអ្នកធ្វើការអត្ថាធិប្បាយនូវការឆ្លើយតបដែលកំនាព្យនេះ អាចទាញចេញពីអ្នកស្តាប់ ។

---